# ធម្មទេសនារបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ
# ពិធីអធិដ្ឋានលើកលែងទោសឲ្យរួចពីបាបដ៏ពេញលក្ខណៈ
# ទីក្រុងរ៉ូម ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០
## តើអ្នករាល់គ្នាមិនទាន់មានជំនឿទេឬ?

**ដំណឹងល្អ៖ ម៉ាកុស៤,៣៥-៤១**

ព្រះយេស៊ូមានព្រះបន្ទូលទៅពួកសាវ័កថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យដូច្នេះ? អ្នករាល់គ្នាមិនទាន់មានជំនឿទេឬ?»។ មក ៤,៤០

បងប្អូនជាទីស្រឡាញ់!

គម្ពីរដែលយើងបានស្តាប់អំបាញ់មិញ ចាប់ផ្តើមដោយពាក្យ "**នៅល្ងាចថ្ងៃនោះដែរ ព្រះយេស៊ូមានព្រះបន្ទូលទៅក្រុមសាវ័ក**"។ តាមពិតយើងមើលឃើញ ប៉ុន្មានសប្តាហ៍កន្លងមកនៅក្នុងពិភពលោកយើងនេះ បីដូចជាភាពងងឹតកំពុងធ្លាក់នៅគ្រប់ទីកន្លែង នៅតាមផ្លូវ នៅតាមទីក្រុង នៅកន្លែងដែលយើងជួបជុំគ្នា ណែនាំឲ្យជីវិតរបស់យើងដូចជាចូលនៅក្នុងភាពសម្ងាត់ នៅក្នុងភាពស្ងៀមស្ងាត់ដែលណែនាំឲ្យអ្វីៗទាំងអស់ស្ទះគាំងនៅក្នុងជីវិតរបស់យើង។ យើងកំពុងភ័យខ្លាច យើងកំពុងវង្វេងដែរ ប្រហែលដូចជាក្រុមសាវ័កក្នុងគម្ពីរដំណឹងល្អនៅពេលហ្នឹង នៅពេលមានខ្យល់ព្យុះមកដល់គេដូចជាមិនបានត្រៀមខ្លួនមុន ណែនាំឲ្យគេភ័យខ្លាចមិនដឹងធ្វើអ្វី។ សម្រាប់យើងក៏ដូចគ្នាដែរ យើងយល់ថាសំពៅរបស់យើងដូចជាតូចតាច រកមិនឃើញផ្លូវយ៉ាងច្បាស់។ ប៉ុន្តែ នៅក្នុងពេលវេលានេះយើងដឹងថាយើងទាំងអស់គ្នាត្រូវតែថែរទូករួមគ្នា យើងត្រូវការផ្តល់កម្លាំងកាយកម្លាំងចិត្តឲ្យគ្នាទៅវិញទៅមក លើកទឹកចិត្តឲ្យគ្នាទៅវិញទៅមក។ នៅលើសំពៅនេះ យើងនៅទាំងអស់គ្នាដែរ តាមពិតយើងមើលនៅយប់នោះក្រុមសាវ័កមានសម្លេងតែមួយ "**យើងវង្វេងអស់ហើយ តើយើងធ្វើដូចម្តេចដើម្បីទៅមុខទៀត?**" យើងក៏ដូចគ្នាដែរ យើងយល់ថាប្រសិនបើយើងចង់ទៅមុខតទៅទៀត យើងត្រូវតែទៅមុខរួមគ្នា យើងមិនអាចទៅម្នាក់ឯងបានទេ។

ពេលយើងស្តាប់គម្ពីរនេះ វាភ្ជាប់នឹងជីវិតរបស់យើងសព្វថ្ងៃ ក៏ប៉ុន្តែយើងពិបាកយល់អំពីរបៀបព្រះយេស៊ូ ក្រុមគ្រីស្តទូតគេកំពុងភ័យខ្លាច គេកំពុងអស់សង្ឃឹម នៅពេលនោះព្រះយេស៊ូកំពុងដេកលក់។ ដូចជាព្រះយេស៊ូមិនបានចាប់អារម្មណ៍ទេ លើកទីមួយដែលយើងឃើញព្រះយេស៊ូកំពុងដេកលក់នៅក្នុងគម្ពីរដំណឹងល្អ។ ពេលព្រះយេស៊ូភ្ញាក់ពីដេក បានណែនាំឲ្យខ្យល់ព្យុះនៅស្ងៀមស្ងាត់ នៅពេលនោះបីដូចជាព្រះយេស៊ូបានស្តីឲ្យគេ "**ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យដូច្នេះ អ្នករាល់គ្នាមិនទាន់មានជំនឿទេឬ?**" ឲ្យយើងយកចិត្តទុកដាក់ដើម្បីយល់អំពីអត្ថន័យ

នៃការខ្វះជំនឿ ប្រហែលក្រុមសាវ័កគេមិនបានលះបង់ជំនឿរបស់គេ ប៉ុន្តែគេចេះតែសុំដោយថា "**ឱព្រះយេស៊ូអើយ យើងវង្វេងអស់ហើយ លោកគ្រូយើងស្លាប់ឥឡូវហើយ លោកមិនអើពើទេឬ?**"។ ប្រហែលនៅក្នុងក្រុមគ្រួសារយើង អ្វីដែលណែនាំឲ្យយើងពិបាកចិត្តជាងគេ គឺនៅពេលមានសមាជិកនៃគ្រួសារយើងណាម្នាក់ថា មើលប៉ាឯង ម៉ាក់ឯង ពូឯង មិញឯង... មិនអើពើនឹងខ្ញុំសោះ នេះណែនាំឲ្យយើងឈឺចិត្តមែនទែន។

តាមពិតខ្យល់ព្យុះនេះបង្ហាញអំពីភាពទន់ខ្សោយរបស់យើង បង្ហាញអំពីជីវិតរបស់យើង ដែលជួនកាលចេះតែសាងសង់លើកាលវិភាគ លើគម្រោងការ លើទម្លាប់ លើអាទិភាពនេះអាទិភាពនោះ។ ប៉ុន្តែ ណែនាំឲ្យយើងយល់ថាយើងបានដេកលក់ យើងបានភ្លេចអ្វីដែលសំខាន់សម្រាប់ជីវិតរបស់យើង អ្វីដែលសំខាន់សម្រាប់សង្គមរបស់យើង។ ប្រហែលខ្យល់ព្យុះត្រូវការណែនាំឲ្យយើងភ្ញាក់ស្មារតី ដើម្បីនឹករលឹកអំពីអ្វីដែលបានចិញ្ចឹមផ្លូវវិញ្ញាណ ព្រលឹងនៃប្រជាជនរបស់យើងពីដើម។ ជួនកាល យើងបានភ្លេចឫសរបស់យើង យើងបានភ្លេចនឹករលឹកការចងចាំនៃបុព្វបុរសរបស់យើង។ ឫសរបស់យើង ការចងចាំនៃបុព្វបុរសរបស់យើងគឺជាកម្លាំងការពារដើម្បីប្រឆាំងនឹងមារសាតាំង ជាពិសេសនៅក្នុងកាលៈទេសៈនិងបរិយាកាសហ្នឹង។ ប្រហែលជួនកាល ដោយសារខ្យល់ព្យុះដែលមាននៅក្នុងជីវិតរបស់យើង យើងដូចជាលាក់ខ្លួននៅក្នុងភាពអាត្មានិយមរបស់យើង យើងចង់តែបង្ហាញរូបរាងខាងក្រៅ ប៉ុន្តែអ្វីដែលសំខាន់បំផុតគឺឲ្យយើងទទួលស្គាល់ថា យើងជាបងប្អូនបង្កើតនៅក្នុងសង្គមនៅក្នុងពិភពលោកទាំងមូល ព្រះយេស៊ូសួរយើងថា "**ហេតុអ្វីបានជាអ្នករាល់គ្នាភ័យខ្លាចដូច្នេះ អ្នករាល់គ្នាមិនទាន់មានជំនឿទេឬ?**"។

បពិត្រព្រះអម្ចាស់ យប់នេះព្រះបន្ទូលរបស់ព្រះអង្គដូចជាប៉ះដួងចិត្តរបស់យើង ចូលនៅក្នុងជីវិតរបស់យើងផ្ទាល់។ នៅក្នុងពិភពលោកដែលព្រះអង្គស្រឡាញ់លើសអ្វីៗទាំងអស់ យើងដឹងថាយើងជាមនុស្សលោក យើងបានដើរលឿនណាស់ (លឿនពេក) ជួនកាលយើងគិតថាយើងជាមនុស្សក្លាហាន យើងមានសមត្ថភាពគ្រប់លក្ខណៈនៅគ្រប់វិស័យទាំងអស់។ ចិត្តលោភលន់របស់យើង ជួនកាលបានណែនាំឲ្យយើងភ្លេចអ្វីដែលសំខាន់ដើម្បីកសាងជីវិតរបស់យើងជាប្រចាំ។ យើងមិនដែលឈប់នៅពេលយើងឃើញព្រះអង្គរំលឹកអំពីអ្វីដែលសំខាន់ យើងឥតបានភ្ញាក់ស្មារតីនៅពេលយើងបានឃើញសង្គ្រាម អយុត្តិធម៌នៅក្នុងពិភពលោក យើងឥតបានស្តាប់លឺសម្រែករបស់អ្នកក្រីក្រ និងរបស់ផែនដីយើងដែលកំពុងឈឺយ៉ាងខ្លាំង។ យើងបានបន្តដើរលើផ្លូវរបស់យើង ដែលមិនបានចាប់អារម្មណ៍អំពីអ្វីៗទាំងអស់ដែលមាននៅជុំវិញយើង ដោយគិតថាប្រហែលយើងត្រូវតែមានសុខភាពល្អជានិច្ច ទោះបីពិភពលោកយើងកំពុងឈឺយ៉ាងខ្លាំង។

ដូច្នេះ នៅពេលនេះដែលយើងកំពុងនៅក្នុងទឹកសមុទ្រដែលមានរលកយ៉ាងខ្លាំង យើងនិយាយដែរ លោកគ្រូ ឱព្រះអម្ចាស់អើយយើងស្លាប់ហើយ សូមភ្ញាក់ស្មារតី នឹងព្រះយេស៊ូបានឆ្លើយដល់យើងថ្ងៃនេះថា **នៅពេលនេះហេតុអ្វីបានជាបងប្អូនភ័យដូច្នេះ បងប្អូនមិនទាន់មានជំនឿទេឬ?** តាមពិតនៅពេលនេះ ព្រះជាម្ចាស់កំពុងត្រាស់ហៅយើង ដើម្បីឲ្យយើងមានជំនឿរឹងមាំថែមទៀត ជំនឿមិនមែនដើម្បីតែជឿលើព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅក្នុងជីវិតរបស់យើង ប៉ុន្តែជាជំនឿដើម្បីឲ្យយើងដើរឆ្ពោះទៅកាន់ព្រះអង្គផ្ទាល់ ដើម្បីយើងទុកចិត្តលើព្រះអង្គផ្ទាល់។ នៅក្នុងរដូវ៤០ថ្ងៃនេះ ព្រះជាម្ចាស់កំពុងត្រាស់ហៅយើង ចូរកែប្រែចិត្តគំនិត សូមត្រឡប់មកវិញអស់ពីដួងចិត្តដល់ខ្ញុំផង។ នៅក្នុងរដូវ៤០ថ្ងៃនេះព្រះអង្គកំពុងត្រាស់ហៅយើង ឲ្យយើងយល់ថាពេលវេលានៃទុក្ខលំបាកនេះទៅជាពេលវេលាដើម្បីជ្រើសរើស។ មិនមែនជាពេលវេលាដើម្បីទទួលកាត់ក្តីនឹងវិនិច្ឆ័យ ប៉ុន្តែជាពេលវេលាដើម្បីជ្រើសរើសអ្វីដែលសំខាន់ ដើម្បីបោះបង់ចោលអ្វីដែលមិនសំខាន់។ ជាពេលវេលាដើម្បីឲ្យផ្លូវនៃជីវិតរកឃើញគោលដៅសាជាថ្មី មានន័យថាដើរឆ្ពោះទៅព្រះអង្គ ដើររួមជាមួយបងប្អូនឯទៀតៗ។ យើងបានឃើញបងប្អូនរបស់យើងយ៉ាងច្រើនដែលជាគំរូ ដោយបានលះបង់ចោលបូជាជីវិតនៅក្នុងការភ័យខ្លាចបច្ចុប្បន្ននេះ។ តាមពិត កម្លាំងនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលសណ្ឋិតលើយើងទាំងអស់គ្នា ដែលកែប្រែជីវិតរបស់យើងដើម្បីឲ្យយើងពោរពេញដោយសេចក្តីក្លាហាន និងសុខចិត្តបូជាជួយលើកទឹកចិត្តបងប្អូនឯទៀតៗ។ ជីវិតរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែលរំដោះយើង ដែលបង្ហាញពីរបៀបដែលជីវិតរបស់យើង សព្វថ្ងៃបានទទួលការលើកទឹកចិត្ត ទទួលការគាំទ្រពីមនុស្សសាមញ្ញធម្មតា ដែលជួនកាលយើងមិននឹករលឹក ប៉ុន្តែជាមនុស្សសាមញ្ញធម្មតាដែលគ្មានឈ្មោះនៅក្នុងការសែត វិទ្យុ ព័ត៌មាននានា ដែលគ្មានឈ្មោះនៅក្នុងការបង្ហាញម៉ូត នៅក្នុងការសរសេរ...។

ប៉ុន្តែ ជាមនុស្សហ្នឹងដែលជាមនុស្សសាមញ្ញធម្មតាបាននឹងកំពុងសរសេរព្រឹត្តិការណ៍ដ៏សំខាន់បំផុតនៃប្រវត្តិសាស្ត្រ គឺគ្រូពេទ្យ គឺអ្នកថែទាំអ្នកជំងឺ គឺបុគ្គលិកនានាដែលធ្វើការនៅតាមមន្ទីរពេទ្យនីមួយៗ អាជីវករដែលកំពុងលក់ដូរតាមផ្សារដើម្បីឲ្យយើងមានម្ហូបប្រចាំ គឺអ្នកដែលកំពុងសម្អាតទីក្រុងនីមួយៗប្រមូលសំរាមតទៅទៀត គឺអ្នកដែលយកចិត្តទុកដាក់ជញ្ជូនឥវ៉ាន់សម្ភារៈតាមផ្ទះ គឺប៉ូលីស ទាហាន អ្នកស្ម័គ្រចិត្ត បូជាចារ្យ បព្វជិតបព្វជីតា ដែលជាមនុស្សសាមញ្ញធម្មតាប៉ុន្តែយល់ថា ឥតមានមនុស្សណាម្នាក់អាចសង្គ្រោះម្នាក់ឯងបានទេ យើងត្រូវតែទីពឹងគ្នាឯង ទីពឹងលើខ្លួនឯង ទីពឹងលើគ្នាទៅវិញទៅមកដើម្បីទៅមុខ ដើម្បីជោគជ័យ។ ហេតុនេះហើយនៅមុខទុក្ខលំបាកនេះប្រហែលយើងអាចវាស់យ៉ាងច្បាស់លាស់ អំពីការអភិវឌ្ឍនៃប្រជាជននីមួយៗ។ យើងនឹករលឹកដល់ការអធិដ្ឋានរបស់ព្រះយេស៊ូ "**ឱព្រះបិតាអើយ សូមឲ្យទាំងអស់គ្នាជាអង្គ**

**តែមួយ ដូចយើងជាអង្គតែមួយ**” ពិតមែនយើងមើលឃើញមានបងប្អូនប៉ុន្មាននាក់ ពីមួយថ្ងៃទៅមួយថ្ងៃមានចិត្តអត់ធ្មត់ សម្តែងសេចក្តីសង្ឃឹម យកចិត្តទុកដាក់ កុំឲ្យយើងភ័យខ្លាចហួសហេតុ ប៉ុន្តែខិតខំឲ្យយើងមានការទទួលខុសត្រូវរួមគ្នា។ យើងឃើញឪពុកម្តាយ លោកតាលោកយាយ គ្រូបង្រៀន ដែលបង្ហាញដល់កូនចៅ សិស្សានុសិស្ស ដោយសកម្មភាពនិងស្នាដៃដ៏សាមញ្ញបំផុតនៅក្នុងជីវិតប្រចាំ។ យើងធ្វើដូចម្តេចដើម្បីប្រឆាំងនឹងការរងគ្រោះ ទុក្ខលំបាក ដែលយើងកំពុងមាន ដើម្បីឲ្យយើងកែប្រែទម្លាប់របស់យើង ឲ្យយើងដើបមុខដើម្បីអធិដ្ឋានដល់ព្រះជាម្ចាស់។

យើងមានបងប្អូនយើងប៉ុន្មាននាក់ ដែលកំពុងអធិដ្ឋាន ដែលកំពុងផ្ញើជីវិត សម្រាប់ផលប្រយោជន៍មនុស្សទាំងអស់ក្នុងពិភពលោកទាំងមូល។ ពិតមែន ការអធិដ្ឋាន និងការបម្រើដោយរបៀបស្ងៀមស្ងាត់ ជាអាវុធរបស់យើងដើម្បីយកឈ្នះលើភាពងងឹតនិងសេចក្តីស្លាប់។ “**ហេតុអ្វីបានជាអ្នករាល់គ្នាភ័យខ្លាចដូច្នេះ អ្នករាល់គ្នាមិនទាន់មានជំនឿទេឬ?**” ជំនឿរបស់យើងរកឃើញប្រភពនៅពេលនឹកឃើញ យើងត្រូវការការសង្គ្រោះ។ យើងមិនអាចសង្គ្រោះយើងផ្ទាល់ខ្លួន នៅពេលយើងកំពុងធ្លាក់ចុះយើងត្រូវការព្រះជាម្ចាស់ យើងត្រូវការផ្កាយដែលព្រះជាម្ចាស់ជាផ្កាយហ្នឹង ណែនាំឲ្យយើងអាចទៅមុខ។

បងប្អូនជាទីស្រឡាញ់ សូមអញ្ជើញព្រះយេស៊ូឲ្យព្រះអង្គចូលនៅក្នុងសំពៅនៃជីវិតរបស់យើង។ បងប្អូនជាទីស្រឡាញ់ សូមផ្ញើការភ័យខ្លាចរបស់យើងទៅលើព្រះអង្គ ដើម្បីឲ្យព្រះអង្គឈ្នះការភ័យខ្លាចនេះទាំងអស់។ ដូចក្រុមគ្រីស្តទូតពីដើម យើងនឹងធ្វើបទពិសោធន៍ដែលព្រះយេស៊ូគង់នៅជាមួយយើង ដែលព្រះអង្គណែនាំឲ្យយើងមិនធ្លាក់ចុះ មិនឲ្យលិចទឹក ព្រះយេស៊ូណែនាំឲ្យយើងទៅមុខ។ ពិតមែន ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដែលជាព្រះបិតារបស់យើង គឺបើកផ្លូវដើម្បីឲ្យយើងទាំងអស់ដើរឆ្ពោះទៅរកអំពើល្អ ដើម្បីឲ្យអ្វីទាំងអស់ដែលកំពុងកើតឡើងទោះបីមានទុក្ខលំបាក ការព្រួយបារម្ភ ណែនាំឲ្យយើងរកឃើញអំពើល្អថែមទៀត។ ពិតមែន ព្រះបិតារបស់យើងណែនាំឲ្យយើងមានសេចក្តីសុខនៅក្នុងខ្យល់ព្យុះនៃជីវិតរបស់យើង ដោយដឹងថាព្រះជាម្ចាស់ដ៏មានជីវិតគង់នៅមិនអាចសោយទិវង្គតបានទេ។ នៅពេលនេះ ព្រះជាម្ចាស់ត្រាស់ហៅយើងដើម្បីក្នុងភាពងងឹតនៃជីវិតរបស់យើង យើងភ្ញាក់ស្មារតីឲ្យយើងមានសកម្មភាពរួមគ្នាមានសាមគ្គីភាព ដើម្បីឲ្យយើងពោរពេញដោយសេចក្តីសង្ឃឹមតទៅទៀត ឲ្យយើងលើកទឹកចិត្តគ្នាទៅវិញទៅមក នៅក្នុងពេលវេលាដែលយើងមានអារម្មណ៍ថាយើងបាត់បង់អ្វីៗទាំងអស់។ នៅពេលនេះ ព្រះអង្គភ្ញាក់ដើម្បីឲ្យយើងភ្ញាក់ស្មារតី ឲ្យជំនឿរបស់យើងលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញកើនឡើងវិញ។ យើងដឹងថា យើងមានព្រះឈើឆ្កាងដោយសារព្រះឈើឆ្កាងយើងបានទទួលការសង្គ្រោះ យើងមានផ្លូវមួយដោយសារព្រះឈើឆ្កាងយើងបានទទួលជីវិត និង

ព្រះអង្គបានរំដោះយើង យើងមានសេចក្ដីសង្ឃឹមដោយសារព្រះឈើឆ្កាង ព្រះអង្គបានបង្កើតយើងសាជាថ្មី ដើម្បីកុំឲ្យមានអ្វីមកបំបែកយើងចេញពីសេចក្ដីស្រឡាញ់របស់ព្រះអង្គ។

ហេតុនេះហើយ នៅក្នុងភាពឯកោ នៅក្នុងទុក្ខលំបាកដែលយើងកំពុងជួបនៅពេលនេះ ដោយសារយើងមិនអាចជួបជុំគ្នាជាមួយបងប្អូន ប្រហែលយើងខ្វះការលើកទឹកចិត្តផ្ទាល់ យើងខ្វះសេចក្ដីស្រឡាញ់ផ្ទាល់ យើងខ្វះការថ្នាក់ថ្នម...។ ប៉ុន្តែ យើងដឹងថានៅពេលនេះយើងធ្វើបទពិសោធន៍នៃការខ្វះទាំងនេះ ណែនាំឲ្យយើងមើល ឲ្យយើងស្តាប់លឺ ឲ្យយើងទទួលដំណឹងល្អដែលសង្គ្រោះយើង ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញគង់នៅជាមួយយើង និងធ្វើដំណើរជាមួយយើងតទៅទៀត។ នៅពេលនេះ ព្រះយេស៊ូដែលនៅលើឈើឆ្កាងកំពុងទូលអង្វរយើង ឲ្យយើងរកឃើញជីវិតដែលកំពុងទន្ទឹងរង់ចាំយើង ឲ្យយើងសម្លឹងមើលដល់បងប្អូនដែលកំពុងទន្ទឹងរង់ចាំសេចក្ដីសង្ឃឹមពីយើង លើកទឹកចិត្តយើងដើម្បីឲ្យយើងបន្តដំណើរតទៅទៀត។ ដូច្នេះ កុំឲ្យយើងបិទភ្លើងនៃជីវិតដែលកំពុងខ្សោយ ផ្ទុយទៅវិញឲ្យយើងណែនាំសេចក្ដីសង្ឃឹមភ្លឺសាជាថ្មី។

# ពាក្យអធិដ្ឋានសម្រាប់ការលើកលែងទោសដ៏ពេញលក្ខណៈរបស់សម្ដេចប៉ាប

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គជាព្រះអង្គដ៏ពិតប្រាកដ ជាមនុស្សដ៏ពិតប្រាកដ និងមានវត្តមាននៅក្នុងអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត យើងសូមថ្វាយបង្គំព្រះអង្គ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គជាព្រះសង្គ្រោះ ព្រះអង្គគង់នៅជាមួយយើងខ្ញុំ ដោយមានព្រះហឫទ័យស្មោះត្រង់ចំពោះយើងខ្ញុំ ពោរពេញដោយព្រះហឫទ័យមេត្តាករុណា យើងខ្ញុំសូមថ្វាយបង្គំព្រះអង្គ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គជាព្រះមហាក្សត្រ ជាព្រះអម្ចាស់នៃពិភពលោកទាំងមូល នៃប្រវត្តិសាស្រ្តទាំងអស់ យើងខ្ញុំសូមថ្វាយបង្គំព្រះអង្គ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គបានឈ្នះអំពើបាបនិងសេចក្ដីស្លាប់ទាំងអស់ យើងខ្ញុំសូមថ្វាយបង្គំព្រះអង្គ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គជាមិត្តសម្លាញ់របស់មនុស្សលោក ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ព្រះអង្គគង់នៅនិងអង្គុយខាងស្ដាំព្រះបិតា យើងខ្ញុំសូមថ្វាយបង្គំព្រះអង្គ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គជាព្រះបុត្រាតែមួយព្រះអង្គគត់នៃព្រះបិតា ដែលចុះពីស្ថានបរមសុខដើម្បីសង្គ្រោះយើងខ្ញុំ យើងខ្ញុំជឿលើព្រះអង្គហើយ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គជាបរមគ្រូដែលមើលទុក្ខលំបាករបស់យើងខ្ញុំ យើងខ្ញុំជឿលើព្រះអង្គហើយ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គជាកូនចៀមដែលបានបូជាជីវិតដើម្បីរំដោះយើងខ្ញុំពីអំពើបាបទាំងឡាយ យើងខ្ញុំជឿលើព្រះអង្គហើយ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គជាគ្រូគង្វាលដ៏សប្បុរសដែលបានបូជាជីវិតសម្រាប់ហ្វូងចៀមរបស់ព្រះអង្គ យើងខ្ញុំជឿលើព្រះអង្គហើយ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គជានំបុ័ងដ៏មានជីវិត ជាគ្រូពេទ្យដែលផ្ដល់ជីវិតអស់កល្បជានិច្ច យើងខ្ញុំជឿលើព្រះអង្គហើយ

បពិត្រព្រះអង្គម្ចាស់ ព្រះអង្គមានអំណាចលើមារសាតាំង និងមានអំណាចលើពិភពលោកទាំងមូល ឱព្រះអង្គអើយសូមជួយរំដោះយើងខ្ញុំ

បពិត្រព្រះអង្គម្ចាស់ សូមរំដោះយើងខ្ញុំពីចិត្តលោភលន់និងចិត្តអំនួត

បពិត្រព្រះអង្គម្ចាស់ សូមរំដោះយើងខ្ញុំពីការភ័យខ្លាចហួសហេតុ

បពិត្រព្រះអង្គម្ចាស់ សូមរំដោះយើងខ្ញុំពីការសង្ស័យនិងការអស់សង្ឃឹម

បពិត្រព្រះអង្គម្ចាស់ សូមរំដោះយើងខ្ញុំពីចិត្តរឹងរូស និងពីការអសមត្ថភាព ដើម្បីស្រឡាញ់បងប្អូនឯទៀតៗ

បពិត្រព្រះអង្គម្ចាស់ សូមសង្គ្រោះយើងខ្ញុំដោយរំដោះយើងខ្ញុំពីទុក្ខលំបាកទាំងអស់ដែលបៀតបៀនមនុស្សលោកសព្វថ្ងៃ

បពិត្រព្រះអង្គម្ចាស់ សូមសង្គ្រោះយើងខ្ញុំដោយរំដោះយើងខ្ញុំពីភាពទុរគត ពីចិត្តអាត្មានិយម

បពិត្រព្រះអង្គម្ចាស់ សូមសង្គ្រោះយើងខ្ញុំដោយរំដោះយើងខ្ញុំពីជំងឺនានា ជាពិសេសជំងឺកូវីដ១៩ និងពីការភ័យខ្លាចចំពោះបងប្អូនឯទៀតៗដែរ

បពិត្រព្រះអង្គម្ចាស់ សូមសង្គ្រោះយើងខ្ញុំដោយរំដោះយើងខ្ញុំពីអ្វីៗទាំងអស់ ដែលណែនាំឲ្យយើងខ្ញុំវង្វេង ណែនាំឲ្យយើងខ្ញុំគិតតែពីផលប្រយោជន៍ដោយគ្មានចិត្តអាណិតមេត្តា អំពីអំពើហិង្សាទាំងឡាយ

បពិត្រព្រះអង្គម្ចាស់ សូមសង្គ្រោះយើងខ្ញុំដោយរំដោះយើងខ្ញុំពីការកុហក់ ពីព័ត៌មានមិនពិត

បពិត្រព្រះអង្គម្ចាស់ សូមលើកទឹកចិត្តយើងខ្ញុំដោយមើលឃើញព្រះសហគមន៍ដែលកំពុងឆ្លងវាលរហោស្ថានសព្វថ្ងៃ

បពិត្រព្រះអង្គម្ចាស់ សូមលើកទឹកចិត្តយើងខ្ញុំដោយមើលឃើញមនុស្សដែលកំពុងភ័យខ្លាច

បពិត្រព្រះអង្គម្ចាស់ សូមលើកទឹកចិត្តយើងខ្ញុំដោយមើលអ្នកជំងឺ បងប្អូនដែលកំពុងស្លាប់ មនុស្សដែលទទួលការសង្កត់សង្កិនដោយភាពឯកោ

បពិត្រព្រះអង្គម្ចាស់ សូមលើកទឹកចិត្តយើងខ្ញុំដោយមើលឃើញគ្រូពេទ្យ បុគ្គលិកតាមមន្ទីរពេទ្យទាំងអស់ដែលអស់កម្លាំងដោយសារធ្វើការច្រើន

បពិត្រព្រះអង្គម្ចាស់ សូមលើកទឹកចិត្តយើងខ្ញុំដោយមើលឃើញអ្នកដឹកនាំប្រទេសនីមួយៗ នយោបាយ រោងចក្រ សហគ្រិន នៅក្នុងពិភពលោកដែលកំពុងទទួលផ្ទឹមនៃពិភពលោកនូវការសម្រេចចិត្តរបស់ពួកគាត់

នៅពេលយើងខ្ញុំកំពុងទទួលមរណភាព ឬយើងខ្ញុំទទួលបងប្អូនដែលកំពុងស្លាប់ សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់យើងខ្ញុំ

នៅពេលយើងខ្ញុំកំពុងទទួលការល្បួង ឬភាពខ្សោយ សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់យើងខ្ញុំ

នៅពេលយើងខ្ញុំកំពុងប្រឆាំងនឹងអំពើបាប និងអំពើអាក្រក់ទាំងឡាយ សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់យើងខ្ញុំ

នៅក្នុងការស្វែងរកអំពើល្អ និងអំណរសប្បាយដ៏ពិតប្រាកដ សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់យើងខ្ញុំ

នៅក្នុងការសម្រេចចិត្តគង់នៅជាមួយព្រះអង្គ និងទទួលមិត្តភាពពីព្រះអង្គ សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់យើងខ្ញុំប្រសិនបើអំពើបាបបៀតបៀនយើង សូមព្រះអង្គប្រទានសេចក្ដីសង្ឃឹមឲ្យយើងខ្ញុំផង

ប្រសិនបើការស្អប់បិទដួងចិត្តរបស់យើងខ្ញុំ សូមព្រះអង្គប្រទានសេចក្ដីសង្ឃឹមឲ្យយើងខ្ញុំផង

ប្រសិនបើទុក្ខលំបាកនិងការឈឺចាប់ចូលនៅក្នុងជីវិតរបស់យើងខ្ញុំ សូមព្រះអង្គប្រទានសេចក្ដីសង្ឃឹមឲ្យយើងខ្ញុំផង

ប្រសិនបើការមិនអើពើណែនាំឲ្យយើងខ្ញុំភ័យខ្លាច សូមព្រះអង្គប្រទានសេចក្ដីសង្ឃឹមឲ្យយើងខ្ញុំផង

ប្រសិនបើសេចក្ដីស្លាប់ចាប់យើងខ្ញុំ សូមព្រះអង្គប្រទានសេចក្ដីសង្ឃឹមឲ្យយើងខ្ញុំផង។